កំនើន ការងារ សមធម៌

# ប្រវត្តិគំនិតសេដ្ឋកិច្ច









ចងក្រងដោយ ជឹម សុជាតិ

# មាតិកា


| | | |
|---|---|---|
| ១. អារម្ភកថា | | ២ |
| ២. អាដាមស្មីថ | Smith | ៥ |
| ៣. កាល់ម៉ាក្ស | Marx | ១៣ |
| ៤. ដាវីដហ្យូម | Hume | ២៥ |
| ៥. ម៉ាស្យល់ | Marshall | ៣៥ |
| ៦. រីកាដូ | Ricardo | ៤០ |
| ៧. វិលរ៉ាស់ | Walras | ៤៣ |
| ៨. ខេន | Keynes | ៤៦ |
| ៩. ហ្វ្រីដមែន | Friedman | ៥១ |
| ១០. សូឡូវ | Solow | ៥៨ |
| ១១. សាមុំអែលសុន | Samuelson | ៦២ |
| ១២. អាកេឡូហ្វ | Akerlof | ៦៧ |
| ១៣.ណាស្យ | Nash | ៧២ |
| ១៤. ម៉ាន់ដែល | Mundell | ៧៧ |
| ១៥. ដុនប៊ុស្ស | Dornbusch | ៨១ |
| ១៦. គ្រុមែន | Krugman | ៨៣ |

# អារម្ភកថា

ជាមួយនឹងការចេះដឹងដ៏តិចតួចស្តួចស្តើងនេះ ខ្ញុំបាទសូមអភ័យទោសដល់ រៀមច្បង សាស្ត្រាចារ្យ អ្នកសេដ្ឋកិច្ច ឬអ្នកសិក្សាសេដ្ឋកិច្ចដូចគ្នា ចំពោះកំហុសឆ្គង នៅក្នុងសៀវភៅនេះ។ ដោយសារតែការយល់ដឹងរបស់ខ្ញុំ នៅមានកម្រិតទៅលើសេដ្ឋកិច្ចវិទ្យា និងបញ្ហាសេដ្ឋកិច្ចជាក់ស្តែង ខ្ញុំបាទមិនជានាសៀវភៅត្រឹមត្រូវតាមគំនិតដើមរបស់អ្នកប្រាជ្ញសេដ្ឋកិច្ចទាំងអស់។

នាពេលបច្ចុប្បន្ននេះ មុខវិជ្ជា Economic Thought និង History of Economics ត្រូវបានបាត់ចេញពីកម្មវិធីសិក្សារបស់សាកលវិទ្យាល័យល្បីៗ នៅសហរដ្ឋអាមេរិក។ ប៉ុន្តែសម្រាប់នៅសាកលវិទ្យាល័យនៅប្រទេសជប៉ុន មុខវិជ្ជា Economic Thought និង History of Economics ត្រូវបានបង្កើនជាមុខវិជ្ជាចាំបាច់ Compulsory និងបង្រៀនបន្ថែម។ អ្នកប្រាជ្ញសេដ្ឋកិច្ចសម័យមុន សុទ្ធសឹងជាអ្នកទស្សនវិជ្ជា និងគណិតវិទ្យា ដែលគាត់មាន Insight និងការយល់ស៊ីជម្រៅ។

ឆ្លៀតក្នុងឱកាសនេះខ្ញុំបាទ សូមថ្លែងអំណរគុណដល់ សាស្ត្រាចារ្យសេដ្ឋកិច្ចរបស់ខ្ញុំ Takagi Shinji, Honda Yuzo នៃ Osaka University និង Iwata Kenji នៃ Kyushu University និងសាស្ត្រាចារ្យដ៏ទៃទៀតមាន សាស្ត្រាចារ្យ Abe, Ban, Urai, Dome, Oya, Kan, Maesono, Saeki, Osumi, Ishida, Osaka និងសាស្ត្រាចារ្យដ៏ទៃទៀត។ ខ្ញុំក៏ដឹងគុណសិស្សច្បង Samreth Sovannroeun, Nong Sovannak, Long Dara, Horn Theara និង Chunly Sereyvicheth ដែលមានឧបការៈគុណដល់ការសិក្សា និងរស់នៅរបស់ខ្ញុំ។ ជាមួយគ្នានេះដែរសូមអរគុណ មិត្តរួមជំនាន់ Tea Seanghy, Ear Chariya និង Chea Vathannak ផងដែរ។

កណ្ដាល ២៣ មករា ២០២២

ជឹម សុជាតិ



# Adam Smith

## Free Economy, Invisible hand, Division of Labor

ද

# អាដាមស្មីថ Adam Smith
# (១៧២៣-១៧៩០)

អ្នកប្រាជ្ញអាដាមស្មីថត្រូវបានគេឲ្យឈ្មោះថាជា **បិតាសេដ្ឋកិច្ច**។ សៀវភៅរបស់គាត់ The Wealth of Nation (ទ្រព្យរបស់ប្រទេស) ជាមួយនិងពាក្យថា បាតដៃអរូបី The Invisible Hand មានភាពល្បីល្បាញយ៉ាងខ្លាំង។

លោកអាដាមស្មីថ កើតនៅស្កុតលែន ដោយកំព្រាឪពុក និងត្រូវបានម្ដាយរបស់គាត់ជំរុញឲ្យប្រឹងប្រែងរៀនសូត្រ។ ក្នុងវ័យ ១៤ ឆ្នាំ គាត់បានចូលរៀនទស្សនវិជ្ជា នៅសាកលវិទ្យាល័យ Glasgow។ មិត្តភក្ដិរបស់គាត់គឺ David Hume ក៏ជាអ្នកទស្សនវិទូដ៏ល្បីល្បាញដែរ។

ក្នុងឆ្នាំ ១៧៥១ លោកអាដាមស្មីថ ត្រូវបានក្លាយជាសាស្ត្រាចារ្យទស្សនវិជ្ជាសាកលវិទ្យាល័យ Glasgow និងឆ្នាំបន្ទាប់

មកគាត់ក្លាយជាសមាជិកនៃសង្គមទស្សនវិជ្ជាEdinburgh។

**១. ទ្រព្យរបស់ប្រទេស (Wealth of Nation)**

នេះជាការយល់របស់ខ្ញុំចំពោះគំនិតរបស់អាដាមស្មីថ ទ្រព្យរបស់ប្រទេស Wealth of Nation គឺជាកម្លាំងពលកម្ម (Labor Force) ដែលមានការប្រឹងប្រែងឧស្សាហ៍ព្យាយាម (Industry) ការឆ្នៃប្រឌិត និងការរៀនសូត្រពង្រឹងសមត្ថភាពជាប្រចាំ។ ជាក់ស្តែងយើងឃើញប្រទេសដែលគេជឿនលឿនគេសម្បូរ សាស្ត្រាចារ្យ វិស្វករ អ្នកទស្សនវិជ្ជា អ្នកច្បាប់ និងកម្មករជំនាញគ្រប់កម្រិត ដែលមាន សហរដ្ឋអាមេរិក ជប៉ុន បារាំង ឬសិង្ហបុរីជាដើម។

នាពេលសព្វថ្ងៃ ដែលគោលនយោបាយ Knowledge Economy, Digital Economy និងឧស្សាហកម្ម 4.0 ដែលត្រូវដាក់ចេញឡើង។

គំនិតសំខាន់របស់អាដាមស្មីថ ក្នុងសេដ្ឋកិច្ចវិទ្យា សម្រាប់សមតា (Equilibrium) គឺជាចំនុចដែលគ្រប់ភាគីទាំងអស់ក្នុងសេដ្ឋកិច្ចដែលមានអ្នកផ្គត់ផ្គង់ និងអ្នកត្រូវការផលិតផល ឯកភាពគ្នាលើចំនុច ដែលបណ្តាលឲ្យផលប្រយោជន៍សេដ្ឋកិច្ច ដោយនឹងមិនផ្លាស់ផ្តូរឥរិយាបទ។ នេះជាគំនិតសេរីនិយមរបស់អាដាមស្មីថ ក្នុងសេដ្ឋកិច្ចទីផ្សារសេរី។

## ២. បាតដៃអរូបី The Invisible Hand

បើយើងចម្លងឃ្លាដែលមានពាក្យ The Invisible Hand ក្នុងស្នាដៃ The Wealth of Nation៖

"By preferring the support of domestic to that of foreign industry, he intends only his own security; and by direction that industry in such manner as its produce may be of the greatest value, he intends only his own gain, and he is in this, as in many other cases, led by

an **invisible hand** to promote an end which was not part of his intention″

មានន័យថា មនុស្សគ្រប់គ្នាក្នុងសង្គមប្រឹងប្រែង កែលម្អសមត្ថភាព និងការប្រកបការងារផលរបរ ទោះបីជាការប្រឹងប្រែងនេះហាក់ដូចជាការដើម្បីផលប្រយោជន៍ផ្ទាល់ខ្លួន ប៉ុន្តែការប្រឹងប្រែងប្រែងនេះ បានជួយឲ្យសង្គមរីកចម្រើន មានវិបុលភាព ទាំងមូលទៅវិញ ដែលការប្រឹងប្រែងម្នាក់ៗនេះ ជាបាតដៃអរូបី ដែលជួយសង្គមទាំងមូល។

## ៣. ការបែងចែកកម្លាំងពលកម្ម Division of Labor

ក្នុងជីវភាពរស់នៅ យើងត្រូវការផលិតផលប្រើប្រាស់ ប៉ុន្តែទោះបីជាយើងអ្នកផលិត យើងមិនអាចផលិតផលទាំងអស់ដើម្បីមកប្រើប្រាស់ខ្លួនឯងដែរ។ ដូច្នេះ យើងត្រូវបែងចែកគ្នាផលិតដែលហៅថា Division of Labor។ ការបែងចែកគ្នាផលិតនេះ

ហើយ ដែលធ្វើឲ្យសង្គមរីកចម្រើន ដោយកំលាំងពលកម្មធ្វើការ Specialization លើការផលិត ផលិតផលផ្សេងគ្នា។

ក្រោយពីបានផលិតផលពី Division of Labor យើងក៏ចាប់ផ្តើមផ្តោះផ្តូរផលិតផលគ្នា (Exchange) ដែលត្រូវការ លុយ (Money) ជាមធ្យោបាយនៃការផ្តោះផ្តូរ។

អាដាមស្មីថ បានសង្កត់ធ្ងន់ វត្តមាននៃលុយ (Money) ក៏ជាកត្តាសំខាន់នៃការរីកចម្រើនសង្គមស៊ីវិល័យ ដែលលុយអាចរក្សាតម្លៃបាន ដែលធ្វើឲ្យមនុស្សប្រឹងប្រែងធ្វើការដើម្បីរកលុយ។

## ៤. តួនាទីរបស់រដ្ឋាភិបាលក្នុងសេដ្ឋកិច្ច

អាដាមស្មីថ មិនចង់ឲ្យរដ្ឋាភិបាលលូកដៃខ្លាំងសេដ្ឋកិច្ច ប៉ុន្តែក្នុងផ្នែកចុងក្រោយនៃ Wealth of Nation គាត់បានកំណត់តួនាទីរបស់រដ្ឋាភិបាល ៣ គឺៈ

- ការពារការវាតទីពីបរទេសដោយកម្លាំងទ័ព

- ថែរក្សាយុត្តិធម៌ក្នុងសង្គម
- កសាងហេដ្ឋារចនាសម្ព័ន សាលារៀន ផ្លូវ ថ្នល់ ប្រលាយទឹក និងអគ្គិសនី។

## ៥. ការពិចារណាអំពីបញ្ហាក្នុងសេដ្ឋកិច្ចសេរី

ការជំរុញសេដ្ឋកិច្ចសេរី ជារឿងដ៏ប្រសើរ ប៉ុន្តែនៅក្នុងសេដ្ឋកិច្ចវិទ្យាសម័យទំនើប យើងរកឃើញ បរាជ័យទីផ្សារ Market Failure។ នៅក្នុងមីក្រូសេដ្ឋកិច្ច Free Competitive នឹងធ្វើឲ្យក្រុមហ៊ុនផ្គត់ផ្គង់មានចំណូលស្មើរសូន្យ។ ឧទាហរណ៍៖ ក្នុងទីផ្សារផលិតផលមួយ ដែលមានផ្គត់ដំបូង ១ ក្រុមហ៊ុន ដែលតម្រូវការ ១០០ ផលិតផល ដែលតម្លៃលក់ទិញផលិត ២$ ក្នុង ១ ផលិតផល និងក្រុមហ៊ុនចំនាយផលិត ១$ ក្នុង ១ ផលិតផល។ ដូចនេះក្រុមហ៊ុនរកចំនូល បាន ១០០$។ ដោយឃើញក្រុមហ៊ុនទី ១ រកចំនូលក្នុងទីផ្សារបាន ក្រុមហ៊ុន ១ ទៀតបានចូលដែរ។ បើសិនកាត់ចំនែកទីផ្សារស្មើគ្នា ក្រុមហ៊ុន ទាំង ២ បានចំនូល ៥០$ ម្នាក់ៗ។ ចុះបើចំនួនក្រុមហ៊ុនផ្គត់ផ្គង់ បានកើន ៤ ឬ៨

ឬ១០ ជាចុងក្រោយ ក្រុមហ៊ុនទាំងអស់ នឹងមិនអាចរកចំនូល ដើម្បីទប់ទល់ Fixed Cost របស់ការផលិតរបស់ខ្លួន។

សម្រាប់ជាគោលនយោបាយឧស្សាហកម្ម រដ្ឋអាចមាន លទ្ធភាពមិនឲ្យក្រុមហ៊ុនច្រើនពេកចូលក្នុងទីផ្សារផលិតផលណា មួយ តាមរយៈការកំណត់ចំនួនអាជ្ញាបណ្ណ ក្នុងការបើកក្រុមហ៊ុន ថ្មី។



Karl Marx

Surplus Value, Capital, Reproduction

# កាល់ម៉ាក្ស Karl Marx
# (១៨១៨-១៨៨៣)

លោកកាល់ម៉ាក្ស កើតនៅប្រទេសអាឡឺម៉ង់ និងបានចូលរៀនច្បាប់និងទស្សនវិជ្ជា នៅសកលវិទ្យាល័យ Bonn ។ ដោយសារការសរសេររបស់គាត់ គាត់ត្រូវបានបណ្តេញចេញ ពីប្រទេសអាឡឺម៉ង់ ហើយទៅរស់នៅទីក្រុងឡុង ប្រទេសអង់គ្លេស។ ស្នាដៃរបស់គាត់ The Communist Manifesto ជាមួយ អង់ហ្គេល និង Das Capital មានភាពល្បីល្បាញ ដែលគេហៅទ្រឹស្តីកុម្មុយនីស្ត ម៉ាក្ស អង់ហ្គេល។

## ១. តម្លៃ ២ របស់ផលិតផល

ទ្រឹស្តីអំពីតម្លៃនៃផលិតផល Commodity ត្រូវបាអ្នកសេដ្ឋកិច្ចភាគច្រើ បានវិភាគ ដែលបានឯកភាពគ្នាគិតថា តម្លៃកំលាំងពលកម្ម ដែលបានផលិតផលិតផលនោះ។

យោងតាម កាល់ម៉ាក្ស ផលិតផលមានតម្លៃ ២ គឺតម្លៃសម្រាប់ប្រើប្រាស់ ( Value in Use ) និងតម្លៃសម្រាប់ផ្ទូរ ( Value in Exchange )។

តម្លៃដែលអាចប្រើប្រាស់បានរបស់ផលិតផលមានដូចជា ក្រដាសសម្រាប់ព្រីន រថយន្តសម្រាប់បើក ទឹកសម្រាប់ផឹក ជាដើម ដែលត្រូវគិតទៅលើបរិមាណ និងគុណភាព និង Utility សម្រាប់ការប្រើប្រាស់។

តម្លៃសម្រាប់ផ្ទូរ ជាឧទាហរណ៍ បើយើងយកអង្ករ ជាគ្រឿងរង្វាស់ ក្នុងសម័យដែលគេមិនប្រើលុយយើងឃើញថា មាន់ស្រែ ១ ក្បាល=អង្ករ ១០ គក ថ្នាំប៉ារ៉ា ១ គ្រាប់=អង្ករ ២ គក ច្រៀង ១ ពេល= អង្ករ ៣០ គក ជាដើម។

ដើម្បីបង្កើតផលិតផលដែលមានតម្លៃប្រើប្រាស់គឺត្រូវការកម្លាំងពលកម្មក្នុងការផលិត។ ប៉ុន្តែមានផលិតផលខ្លះទៀតដែល

មិនត្រូវការកំលាំងពលកម្មក្នុងការផលិតទេ ដូចជាខ្យល់ដកដង្ហើម ដីវដាតិដី ជាដើម។

## ២. តម្លៃលើស (Surplus Value)

គំនិតសំខាន់ដែលខ្ញុំនមានការពេញចិត្តរបស់ទ្រឹស្តីសេដ្ឋកិច្ចរបស់កាល់ម៉ាក្សគឺ តម្លៃលើស Surplus Value នេះ។ ក្នុងរូបមន្ត **M—G—M´** ដែល M ជាចំនួនលុយ ទិញផលិតផល G (Goods) ហើយលក់តម្លៃលើស M ជា M´។ ឧទាហរណ៍៖ ពាណិជ្ជករណ៍ម្នាក់ ប្រើលុយ ទិញផលិតផលមួយគ្រឿងក្នុងតម្លៃ ១០០$ ហើយដាក់លក់ ១២០$ ដូចនេះតម្លៃលើស ២០$ ដែលពាណិជ្ជករនេះបានកេងចំនេញពីទីផ្សារ។ តម្លៃលើស ដែលបន្ថែមលើតម្លៃផលិតផល មិនមែនជាតម្លៃកំលាំងពលកម្មឡើយ។

មនុស្សក្នុងសង្គមដើម្បីរស់រានបាន បានលក់កម្លាំងពលកម្មរបស់ខ្លួនទៅឲ្យអ្នកមូលធន (Capitalist) ដែលមធ្យោបាយផលិតកម្មដូចជា រោងចក្រ និងគ្រឿងម៉ាស៊ីនជាដើម។ ការលក់

កំលាំងពលកម្មក៏ត្រូវយោលទៅតាមច្បាប់នៃតម្រូវការនិងផ្គត់ផ្គង់ដែរ ដោយពិនិត្យទៅលើគុណភាពនៃការធ្វើការរបស់កម្លាំងពលកម្ម។

ប៉ុន្តែយោងតាមកាល់ម៉ាក្ស អ្នកមូលធន (Capitalist) បានកេងប្រវ័ញ្ចកម្លាំងពលកម្ម ដែលជាតម្លៃលើស។ ឧទាហរណ៍៖ កម្មករធ្វើការ ១ ថ្ងៃ ១០ ម៉ោង។ ប៉ុន្តែម៉ោងគាត់ធ្វើការ ៦ ម៉ោង និងគាត់ទទួលប្រាក់ពលកម្ម គ្រប់គ្រាន់សម្រាប់ការចំនាយការរស់នៅរបស់គាត់។ ដូចនេះ សល់ ៤ ម៉ោង គឺជាម៉ោងលើស ដែលអ្នកមូលធនបានចំនេញលើគាត់។

## ៣. សមីការផលិតឡើងវិញនៃមូលធន (Formula for Capital Reproduction)

យោងតាមកាល់ម៉ាក្ស W ជាតម្លៃ ផលិតផលទាំងមូល C ជាចំនាយមូលធនថេរ ដូចជាវត្ថុធាតុដើម គ្រឿងម៉ាស៊ីន ដែលមិនប្រែប្រួល V ជាចំនាយប្រែប្រួល ទៅលើការជួលកម្លាំងពលកម្ម M

ជាតម្លៃលើស សម្រាប់ការចំនេញរបស់អ្នកមូលធន ម្ចាស់ផលិតកម្ម។ ឧបមាក្នុងសេដ្ឋកិច្ច យើងមាន ២ វិស័យដែលផលិតផល ២ ដែលយើងមានសមីការដូចខាងក្រោម៖

$W_1=C_1+V_1+M_1$

$W_2= C_2+V_2+M_2$

បានន័យថា តម្លៃផលិតផលគឺជារួមបញ្ចូលគ្នា ការចំនាយគ្រឿងម៉ាស៊ីនវត្ថុធាតុដើម កម្លាំងពលកម្ម និងការចំនេញរបស់អ្នកមូលធន។

ប៉ុន្តែដើម្បីឲ្យផលិតកម្មដំណើរការបាន ត្រូវមានលក្ខខណ្ឌដូចខាងក្រោម៖

$C_1+V_1+M_1= C_1+ C_2$

$\mathbf{V_1+M_1= C_2}$

សមីការនេះហៅថា លក្ខខណ្ឌក្នុងការផលិតសមញ្ញ Simple Capital Reproduction ដែលបានន័យថា ដើម្បីផលិតទៅមុខទៀតដែលត្រូវការមូលនិធថ្មី $C_2$ គឺត្រូវការវិនិយោគ ដែលបានមកពី ការចំនេញរបស់អ្នកមូលធន $M_1$ និងកម្លាំងពលកម្ម $V_1$ ពិវិស័យផ្សេងគ្នា ដែលជាការលក់ផលិតផលទៅវិស័យនុះ។

ប៉ុន្តែដើម្បីពង្រីកទៅមុខនៃផលិតកម្ម យើងត្រូវតែ៖

$V_1+M_1> C_2$

ដូចនេះអត្រានៃការចំនេញរបស់អ្នកមូលធន r គឺ៖

$$r = \frac{M}{C+V} = \frac{\frac{M}{V}}{\frac{C}{V}+1}$$

$\frac{M}{V}$ ជាអត្រានៃតម្លៃលើស Surplus Value។ បើ $\frac{M}{V}$ មិនប្រែប្រួល និងចំណូលកើនឡើង ដូចនេះ $\frac{C}{V}$ ត្រូវថយចុះ។

## ៤. ទ្រឹស្តីកុម្មុយនិស្ត The Communist Manifesto

Communist Manifesto ត្រូវបានសរសេរដោយ ម៉ាក្ស-អែនហ្គែល ក្នុងឆ្នាំ ១៨៤៨ ដែលមានបំណងឲ្យកម្លាំងពលកម្ម Labor ធ្វើជាម្ចាស់មធ្យោបាយផលិតកម្ម។

ចំនុចនៃ The Communist Manifesto មានដូចជា៖

- កម្រិត ឬបំបាត់កម្មសិទ្ធឯកជន
- បង្កើតឧស្សាហកម្ម ដែលគ្រប់គ្រងដោយរដ្ឋ
- ទាមទារកម្មសិទ្ធដី ឬមធ្យោបាយផលិតកម្មពីម្ចាស់ដីធំៗ
- រឹបអូសទ្រព្យសម្បត្តិពីអ្នកបះបោរ និងអ្នកអន្តោរប្រវេស
- រៀបចំរចនាសម្ព័ន្ធគាំទ្រដល់កម្លាំងពលកម្ម
- អប់រំកុមារដោយសិទ្ធស្មើរគ្នា
- កសាងមជ្ឈមណ្ឌលសម្រាប់សុខមាលភាពបុគ្គល
- បែងចែកទ្រព្យសម្បត្តិស្មើរគ្នា

## ៥. បទពិចារណារបស់ទ្រឹស្តីសេដ្ឋកិច្ចរបស់កាល់ម៉ាក្ស

យើងឃើញថាទ្រឹស្តីនៃតម្លៃលើស Surplus Value មានន័យសំខាន់ក្នុងសេដ្ឋកិច្ច។ ដូចជាសព្វថ្ងៃនៃ Bubble តម្លៃដី ដែលទិញ ១០០០$ ក្រោយមក ២០ ឆ្នាំ លក់បាន ១ លាន$ តម្លៃលើស ១ លាន$ មានន័យយ៉ាងដូចម្ដេច បើសិនជាដីមិនបានក្លាយជាដីសម្រាប់រោងចក្រ ហើយគ្រាន់តែទិញដើម្បីលក់ ២ លាន$ វិញ ?

លោក កាល់ម៉ាក្ស ប្រហែលមានការគិតគូរ ដល់ការលំបាករបស់ជីវិភាពកម្មករក្នុងសម័យបដិវត្តន៍ឧស្សាហកម្ម។ ប៉ុន្តែយើងឃើញការដួលរលំនៃសហភាពសូវៀត ដែលរដ្ឋជាម្ចាស់នៃផលិតកម្ម កុំថាទៅដលកម្មករជាម្ចាស់នៃផលិតកម្ម និងការងាកទៅកាន់សេដ្ឋកិច្ចសេរីរបស់មហាអំណាចចិន បានធ្វើឲ្យចិនក្លាយជាមហាអំណាចសេដ្ឋកិច្ចទី ២ ក្នុងលោក។ ការដំណើរការរោងចក្រដោយរដ្ឋ គឺមានការ Free Rider ដោយខុសប្លែក ពីការផលិតដោយវិស័យឯកជនដែលគិតពី គុណភាព និងទីផ្សារ។

ចំពោះ The Communist Manifesto ដែលថានឹងបំបាត់កម្មសិទ្ធឯកជន និងការរស់នៅរួម ជារឿងដែលខុស នឹងធម្មជាតិនៃមនុស្សរស់នៅក្នុងសង្គម ដែលចង់បានភាពផ្ទាល់ខ្លួន និងការកែលម្អរចង់មានចង់បាន។

កាល់ម៉ាក្ស ជាអ្នកទស្សនវិទូ អ្នកសេដ្ឋកិច្ច អ្នកវិភាគសង្គម ប៉ុន្តែគាត់បានរស់នៅក្នុងភាពក្រីក្រ ដោយកូនរបស់គាត់បានស្លាប់ដោយសារជំងឺ និងភាពក្រីក្រ។

កម្មករមិនអាចជាម្ចាស់ផលិតកម្មបានទេ ដោយសារកម្មករ មិនមានមូលធន ជាទឹកប្រាក់ គ្រឿងម៉ាស៊ីន និងរោងចក្រ មិនមានការធ្វៃប្រឌិត ការគ្រប់គ្រង ការរក និងវិភាគទីផ្សារ។

ចំពោះការធ្វើការរោងចក្រឬក្រុមហ៊ុនសម័យបច្ចុប្បន្ន ការធ្វើការលើសម៉ោង OT ត្រូវបានទទួលកម្រៃ និងស្ថានភាពការងារប្រសើរជាង សតវត្សទី១៩។ កម្មករ ឬបុគ្គលិក ត្រូវប្រឹងប្រែងដើម្បីរោងចក្រ ឬក្រុមហ៊ុន បើរោងចក្ររលំ កម្មករត្រូវអត់កាងារដែរ។



ស្ថានភាពការងាររោងចក្រក្នុងសតវត្សទី១៩



David Hume

# Free Trade, Adjustment, Human Nature

# ដាវីដហ្យូម David Hume
# (១៧១១-១៧៧៧)

ដាវីដហ្យូម ជាអ្នកអ្នកទស្សនវិទូ អ្នកសេដ្ឋកិច្ច និងអ្នកសេរីនិយម ដ៏ល្បីល្បាញ។ ស្នាដៃរបស់គាត់ Treatise of Human Nature ជាវណ្ណកម្មដ៏ល្បីល្បាញក្នុងពិភពទស្សនៈវិជ្ជា។ ពេលគាត់អាយុបាន ១២ ឆ្នាំ គាត់បានចូលរៀនសាកលវិទ្យាល័យ Edinburgh ដែលជាអាយុទាប ជាង ១៤ ឆ្នាំបានឲ្យចូលមហាវិទ្យាល័យ។ ក្នុងពេលអាយុ បាន ២៥ ឆ្នាំ ក្រោយពីឥតការងារធ្វើ ដាវីហ្យូម បានចូលធ្វើការនៅបណ្ណាល័យ សាកលវិទ្យល័យ Edinburgh ជាអ្នកសរសេរអត្ថបទ (Essayist)។ គាត់បានសរសេរសៀវភៅល្បីល្បាញជាច្រើនដូចជា៖ *Essays, Moral, Political, and Literary; Essays, Moral, Political, and Literary Philosophical; Essays Concerning Human*

*Understanding*, *The History of England*។ លោក ដាវីហ្យូម ជាមិត្តភក្តិរបស់ លោក អាដាមស្មីថ។

## ១. មូលដ្ឋាននៃសង្គមស៊ីវិល័យ

លោក ដាវីដហ្យូម បាននិយាយពីមូលដ្ឋាននៃសង្គមស៊ីវិល័យ មាន ២ គឺៈ កម្មសិទ្ធឯកជន និងការបង្កើនបច្ចេកវិជ្ជាផលិត។ កត្តាទាំងពីរនេះ ក៏ជាមូលដ្ឋានៃការគ្រប់គ្រងរដ្ឋ។ រដ្ឋត្រូវតែថែរក្សា កម្មសិទ្ធឯកជន ការផ្ទេរកម្មសិទ្ធ និងការគោរពកិច្ចសន្យា ដែលមានដូចកិច្ចសន្យាទិញដូរ ពាណិជ្ជកម្ម។ កិច្ចសន្យាជាមូលដ្ឋានក្នុងការគ្របគ្រងសេដ្ឋកិច្ចសេរី។

ដើម្បីឲ្យបានសង្គមស៊ីវិល័យ ឬជាសង្គមដែលមានអារិយធម៌ គឺទាមទារឲ្យ មនុស្សក្នុងសង្គមនោះ ទំនាក់ទំនងល្អ មានការអភិវឌ្ឍគុណធម៌ និងមនុស្សធម៌។ តាមគំនិតរបស់ដាវីដហ្យូម គុណធម៌ សីលធម៌ និងជំនាញបច្ចេកទេស ត្រូវការហ្វឹកហាត់ ឬការហ្វឹកហាត់ជាផ្លូវការ ដែលជាប្រព័ន្ធអប់រំ។

ក្នុងការកំណត់តួនាទីរបស់រដ្ឋ ដោយដាវីដហ្យូមមានលក្ខណៈដូចអាដាមស្មីថ ដែលមាន ការការពារពីការរំលោភបំពានពីបរទេស ការពាររដ្ឋប្រហារ និងការការពារសេរីភាពរបស់ប្រជាជន។

## ២. ទ្រឹស្តីបរិមាណលុយ Quantity Theory of Money

Quantity Theory of Money ជាទ្រឹស្តីល្បីល្បាញមួយក្នុងសេដ្ឋកិច្ច ដែលបានលើកជាដំបូងដោយ ដេវីដហ្យូម ដែលមានន័យថា៖ ***អតិផរណា (ថ្លៃទំនិញកើនឡើង) គឺស្របតាមការផ្គត់ផ្គង់បរិមាណលុយ (Money Supply) ក្នុងសេដ្ឋកិច្ច*** ។

មធ្យោបាយការផ្គត់ផ្គង់បរិមាណលុយក្នុងសេដ្ឋកិច្ចដោយរដ្ឋ មានដូចជា៖

- ការឲ្យកំចីពីធនាគារកណ្តាលទៅធនាគារឯកជន តាមយៈការបញ្ចុះការប្រាក់ Discount Rat។

- ការបញ្ចុះអត្រា Reserve Requirement របស់ធនាគារឯកជន នៅធនាគារកណ្តាល។
- ការទិញមូលបត្ររដ្ឋាភិបាល ឬមូលបត្រឯកជន របស់ធនាគារកណ្តាលពីក្រុមហ៊ុនឯកជន ដែលធ្វើឲ្យក្រុមហ៊ុនឯកជនមានសាច់ប្រាក់។
- Seignoirage ដែលជាភាពចំនេញនៃការបោះពុម្ពលុយពេលអតិផរណាមានកម្រិតទាប។

បើយោងតាម ដាវីហ្យូម ការផ្គត់ផ្គង់លុយមិនធ្វើឲ្យមានកំនើនពិតប្រាកដដល់សេដ្ឋកិច្ចទេ តែបានធ្វើឲ្យកើន ប្រាក់ខែ និងធ្វើឲ្យមានអតិផរណា។

## ៣. ទ្រឹស្តីយន្តការកែតម្រូវដោយមាសលើ ជញ្ជីងទូទាត់ Price–specie Flow Mechanism

ជាទូទៅការធ្វើពាណិជ្ជកម្មក្នុងពិភពលោក មានបញ្ហាឱនភាពជញ្ជីងពាណិជ្ជកម្ម (នាំចូល ច្រើនជាងនាំចេញ) ដែលធ្វើ

ឲ្យទុនបម្រុងធនាគារកណ្តាលធ្លាក់ចុះ ដោយអ្នកនាំចូលទាំងនោះដូរយករូបិបណ្ណអន្តរជាតិ ពីការលក់ផលិតផក្នុងប្រទេសនេះដោយរូបិយបណ្ណក្នុងស្រុក។ ប៉ុន្តែនៅពេលទុនបម្រុងធនាគារកណ្តាល អស់ទុនបម្រុងអន្តរជាតិ នឹងធ្វើឲ្យមានវិបត្តិធ្ងន់ធ្ងរ ដែលហៅថា Balance of Payment Crisis ដូចវិបត្តិហិរញ្ញអាស៊ាន ១៩៩៧ ដែលធនគារកណ្តាលរបស់ថៃ អស់ទុនបម្រុងធនាគារកណ្តាល។

ចំពោះទ្រឹស្តីយន្តការកែតម្រូវដោយមាសលើ ជញ្ជីងទូទាត់ Price–specie Flow Mechanism លោក ដាវីដហ្យូមបានលើកឡើងថា នៅពេលដែល នាំចេញច្រើនជាងនាំចូល មាសនឹងហូរចូលប្រទេសមានអតិរិកពាណិជ្ជកម្មនេះ។ នៅពេលនាំចូលច្រើនជាងនាំចេញមាស នឹងហូរចេញពីប្រទេសដែលមានឱនភាពពាណិជ្ជកម្មនេះ។ បានន័យថា បើតាមខ្ញុំយល់ ពេលដែលអ្នកនាំចូលលក់ផលិតផលនៅប្រទេសនេះហើយ គេនឹងដូរយកមាសទៅ

ប្រទេសគេវិញ។ នៅពេលប្រទេសដែលមានអតិរេកពាណិជ្ជកម្ម នឹងសម្បូរមាស ដែលធ្វើឲ្យមាសចុះថ្លៃ នឹងធ្វើពាណិជ្ជកម្មនាំចេញធ្លាក់ចុះ។ ទ្រឹស្តីយន្តការកែតម្រូវដោយមាសលើ ជញ្ជីងទូទាត់ Price–specie Flow Mechanism គឺនៅពេលពិភពលោកប្រើប្រព័ន្ធមាស Gold Standard ដែលពិភពលោកប្រើមុនសង្គ្រាមលោកលើកទី១។ សព្វថ្ងៃ លុយដុល្លារមានតួនាទី ដូចមាសដែលបានពោលខាងលើ។

នាពេលសព្វថ្ងៃយើងមិនអាចយកមាសដើម្បីទ្រទ្រង់អត្រាផ្តូរប្រាក់បានទេ ដោយសារទំហំពាណិជ្ជកម្មពិភពលោកធំពេក មិនអាចរកមាសគ្រប់គ្រាន់បាន។ សហរដ្ឋអាមេរិកធ្លាប់ធានាអត្រាដូរមាសនឹងដុល្លារ ដោយប្រព័ន្ធ Bretton Wood ប៉ុន្តែបានបិទលែងទទួលការដូរមាសនឹងដុល្លារ ក្នុងឆ្នាំ ១៩៧១ ដែលពិភពលោកលែងមានអត្រាផ្តូរប្រាក់បេរ (Fixed Exchange Rate)។

### ៤. ទ្រឹស្តីធម្មជាតិនៃមនុស្ស (Treatise of Haman Natures)

នៅក្នុងសៀវភៅ Treatise of Haman Natures ដាវីដ ហ្យូម បានចាប់ផ្ដើមថា ការដឹង (Perception) របស់មនុស្សយើង មាន ២ គឺ៖ ចំណាប់អារម្មណ៍ (Impression) និង គំនិត (Idea)។ ចំណាប់អារម្មណ៍ (Impression) គឺសំដៅលើ ការដឹង តាមវិញ្ញាណទាំង ៦ (Sensation) ការចង់បាន (Passion) អារម្មណ៍ (Emotion) ដែលបានចូលការគិតរបស់យើងជាដំបូង បំផុត។ គំនិត (Idea) មានការគិត (Thinking) និង ការរកមូល ហេតុ (Reasoning)។ ហ្យូមបានសង្កត់ន័យថា ចំណាប់អារម្មណ៍ បង្កើត គំនិត (Idea) ប៉ុន្តែ គំនិតមិនអាចបង្កើត ចំណាប់អារម្មណ៍ (Impression) បានទេ។

ឧទាហរណ៍៖ នៅពេលបុរសម្នាក់ឃើញនារីស្រស់ស្អាត ម្នាក់ ជាចំណាប់អារម្មណ៍ (Impression) គាត់ដឹងភ្លាមនារីហ្នឹង ស្អាត គាត់ចាប់ផ្ដើមមាន Passion។ ក្រោយមកគាត់ចាប់ផ្ដើម មាន Idea ថាត្រូវទាក់ទង ឬមិនទាក់ទងនារីម្នាក់ហ្នឹងឬទេ។ គាត់

## ៥. បទពិចារណាអំពីទ្រឹស្តីរបស់ដាវីហ្យូម

ចំពោះទ្រឹស្តីបរិមាណលុយ Quantity Theory of Money ត្រូវបានអ្នកសេដ្ឋកិច្ចសម័យថ្មី Robert Lucas បានលើកមកជាទ្រឹស្តី Neutrality of Money ហើយបានទទួលពានរង្វាន់ណូបែលសេដ្ឋកិច្ច។

ការផ្គត់ផ្គង់រូបិយវត្ថុ (Money Supply) តាមខ្ញុំយល់ គឺមានប្រយោជន៍សម្រាប់សេដ្ឋកិច្ច ទោះបីក្នុងរយៈពេលវែង ការផ្គត់ផ្គង់រូបិយវត្ថុ នឹងធ្វើឡើងអតិផរណាដូចគ្នាក្នុង ១ ឯកតាមេគុណ។ កាលណាយើងបង្កើនរូបិយវត្ថុ នឹងធ្វើឲ្យកើនការវិនិយោគ ដើម្បីបើក និងពង្រីកអាជីវកម្មដែលនឹងបង្កើតការងារ។



Alfred Marshall

Marginal Revolution, Math, Market

# ម៉ាស្យល់ A. Marshal

# (១៨៤២-១៩២៤)

ខ្ញុំអាចនិយាយថា ខេន Keynese ជាបិតាមាក្រូសេដ្ឋកិច្ច និងម៉ាស្យល់ (A. Marshal) ជាបិតាមីក្រូសេដ្ឋកិច្ច។ សៀវភៅរបស់គាត់ The Principle of Economics ល្បីល្បាញនៅអង់គ្លេស និងសហរដ្ឋអាមេរិក និងប្រទេសជាច្រើននៅលើពិភពលោក។ គណិតវិទ្យា និងក្រាមីក្រូសេដ្ឋកិច្ចសព្វថ្ងៃ គឺពឹងផ្អែក លើ Footnote របស់សៀវភៅគាត់ The Principle of Economics។

ម៉ាស្យល់ បានចូលរៀនគណិតវិទ្យា នៅសាកលវិទ្យាល័យ Cambridge និងបានក្លាយជាសាស្ត្រាចារ្យ ទស្សនវិជ្ជា (Moral) នៅ University College។ នៅឆ្នាំ ១៩៨៥ ម៉ាស្យល់ បានក្លាយជាស្ត្រាចារ្យសេដ្ឋកិច្ចនយោបាយសាកលវិទ្យាល័យ Cambridge។

## ១. ភាពយឺត Marshal Elasticity




គំនិតមីក្រូសេដ្ឋកិច្ច ភាពយឺតនៃថ្លៃចំពោះតម្រូវការ Price Elasticity of Demand មានន័យថា តម្រូវការមានការប្រែប្រួលយ៉ាងណា នៅពេលតម្លៃ ផលិតផលមានការប្រែប្រួល។ ជាទូទៅ តម្រូវការមានការកើនឡើងនៅពេលថ្លៃថុចុះ និងផ្ទុយទៅវិញ តម្រូវការថយចុះ បើសិនថ្លៃផលិតផលកើនឡើង។ ប៉ុន្តែមាន

ករណី ដែលមានទំនិញចាំបាច់ ដែលតម្រូវមិនប្រែប្រួលទោះថ្លៃមានការកើនឡើងឬថចុះ ( Inelastic )។

រូបមន្តភាពយឺតនៃថ្លៃចំពោះតម្រូវការ Price Elasticity of Demand៖

$$\varepsilon = \frac{\%\text{ភាពប្រែប្រួលបរិមាណតម្រូវការ}}{\%\text{ភាពប្រែប្រួលថ្លៃ}}$$

ឧទាហរណ៍៖ ខែ មករា តម្លៃភីសា ២$/នំ និងបរិមាណទិញក្នុងហាង ១២០ នំ។ ដល់ខែ កុម្ភៈ តម្លៃភីសាកើន ២,៥$/នំ បរិមាណទិញក្នុងហាង ធ្លាក់ចុះសល់ត្រឹម ១០០ នំ។ ដូចនេះ យឺតនៃថ្លៃចំពោះតម្រូវការ៖

$$\varepsilon = \frac{\frac{100-120}{120}}{\frac{2.5-2.0}{2.0}} = -0.6$$

បានន័យថា បើសិនថ្លៃកើន ១% នឹងធ្វើឲ្យតម្រូវការថយចុះ ០,៦%។

## ២. ផលប៉ះពាល់នៃការតម្លើងពន្ធ




រូបដែលបានបង្ហាញពីផលប៉ះពាលនៃការតម្លើងពន្ធចំពោះអ្នកប្រើប្រាស់និងអ្នកផលិត ស្រដៀងគ្នានឹងរូបក្រាហ្វនឹងសៀវភៅ The Principle of Economics របស់ម៉ាស្សល់។

ដូចរូបបង្ហាញ ដំបូងសមតា នៅថ្លៃ ១០$ ដែលសមតាបរិមាណំនួន ៨៨។ ដល់តម្លើងពន្ធ ៤$ ថ្លៃបានកើនដល់ ១៤$ ដែលថ្លៃ ១៤$ មានសមតា ៨០ ផលិតផល។ ដូចនេះការដាក់ពន្ធធ្វើឲ្យខាត អ្នកផ្គត់ផ្គង់ ២X៨០=១៦០$ និងអ្នកប្រើប្រាស់ខាត ៤X ៨០=៣២០$។




រូបភាពក្នុង Foot Note សៀវភៅរបស់ម៉ាស្សល់

## ៣. ម៉ាស្យល់ Externality

Externality មានន័យសកម្មភាពសេដ្ឋកិច្ចមួយ នឹងជះឥទ្ធិពលល្អដល់ផ្នែកសេដ្ឋកិច្ចផ្សេងទៀត។ បើសិនផ្នែកនៃឧស្សាហកម្មដែលពឹងផ្អែកវត្ថុធាតុដើមគ្នា បើផ្នែកមួយ មានថ្លៃដើមធ្លាក់ចុះ នឹងធ្វើឲ្យផ្អែកផ្សេងទៀត មានការធ្លាក់ចុះនៃថ្លៃដើមដែរ។ ការបំពុលបរិស្ថានជា Externality មិនល្អ ដែលប្រជាជនរស់នៅក្បែររោងចក្រ ដែលបញ្ចេញកាកសំណល់។ គំនិត Externality ត្រូវបានលើកជាដំបូងដោយ ម៉ាស្យល់។

## ៤. បទពិចារណាចំពោះទ្រឹស្តីសេដ្ឋកិច្ចរបស់ A. Marshall

ទ្រឹស្តីមីក្រូសេដ្ឋកិច្ចមានសារៈសំខាន់ក្នុងការវិភាគ អំពីថ្លៃដើមរបស់សហគ្រាសផលិត ដូចជាការសិក្សាពី Marginal Cost, Average Cost និង Fixed Cost ដែលមីក្រូសេដ្ឋកិច្ច ផ្តល់ឲ្យអ្នកសេដ្ឋកិច្ច មានមូលដ្ឋានក្នុងការវិភាគថ្លៃដើម។

ការមានមូលដ្ឋានក្នុងការវិភាគថ្លៃដើម ធ្វើឲ្យម្ចាស់សហគ្រាសអាចមើលឃើញពីសកម្មភាពផលិត ផលិតភាព និងភាពចំនេញរបស់ក្រុមហ៊ុនខ្លួន។




មុខវិជ្ជាមីក្រូសេដ្ឋកិច្ចត្រូវបានរៀនសម្រាប់និស្សិតគ្រប់គ្រងអាជីវកម្មលើមហាវិទ្យាល័យក្នុងពិភពលោកមានឈ្មោះមុខវិជ្ជាថា Managerial Economics។

# រីកាដូ David Ricardo

## ១៧៧២-១៨២៣

រីកាដូជាអ្នកសេដ្ឋកិច្ចល្បីល្បាញក្នុងទ្រឹស្តីពាណិជ្ជកម្មអន្តរជាតិ។ គាត់មានគំនិតដូចអាដាមស្មីថ ដែលកំលាំងពលកម្មជាកត្តាកំណត់តម្លៃផលិតផល ប៉ុន្តែមានកត្តាផ្សេងទៀតដែលកំណត់តម្លៃផលិតផលដូចជាថ្លៃដូល និងបច្ចេកទេសផលិត។

**១. អត្ថប្រយោជន៍ផ្តាច់ Superlative Advantage និងអត្ថប្រយោជន៍ធៀប Comparative Advantage**

ឧទាហរណ៍ថាប្រទេសក្នុងពិភពលោកមាន ២ ប្រទេស ជប៉ុន និងអាមេរិច ដែលផលិតផលេ ២ គឺរថយន្ត និងផ្លែក្រូច។ បើយើគិតការប្រើកំលាំងពលកម្មក្នុងការផលិតផលិតផលនិមួយៗ៖

| | ជប៉ុន | អាមេរិក |
|---|---|---|
| រថយន្ត | ២០ | ៨០ |
| ក្រូច | ២០ | ៤០ |

យើងឃើញថាប្រទេសជប៉ុនមានថ្លៃដើមផលិតតិចជាងអាមេរិកក្នុងមុខទំនិញទាំង ២ មុខហ្នឹង ដូចនេះជប៉ុន មាន Superlative Advantage។

បើយើងប្រៀបការចំនាយទៅលើកំលាំងពលកម្ម៖

$$\frac{l_{car}^{J}}{l_{Org}^{J}} < \frac{l_{Car}^{US}}{l_{Org}^{US}}$$

$$\frac{20}{20} < \frac{80}{40}$$

1<2

ដូចនេះជប៉ុនមាន Comparative Advantage លើសហរដ្ឋអាមេរិក។

## ២. ភាពចំនេញនៃការធ្វើពាណិជ្ជកម្មអន្តរជាតិ

បើយើងប្រៀបតារាងខាងក្រោម អំពីការផលិត សម្រាប់តែប្រើប្រាស់ខ្លួនឯង និងការផលិតដោយ Specialize លើទំនិញដែល

ខ្លួនផលិតអស់ថ្លៃដើមតិច យើងឃើញថាការធ្វើពាណិជ្ជកម្មអន្តរជាតិ ធ្វើឲ្យចំនេញដល់ប្រទេសទាំងសងខាង។

ការផលិតសម្រាប់តែប្រើប្រាស់ក្នុងប្រទេស

| | ជប៉ុន | អាមេរិក | ពិភពលោក |
|---|---|---|---|
| រថយន្ត | ១០០ | ៧៥ | ១៧៥ |
| ក្រូច | ១០០ | ១៥០ | ២៥០ |

ការផលិតដោយ Specialization តាមប្រទេស

| | ជប៉ុន | អាមេរិក | ពិភពលោក |
|---|---|---|---|
| រថយន្ត | ២០០ | ០ | ២០០ |
| ក្រូច | ០ | ៣០០ | ៣០០ |

យើងឃើញថាការផលិតដោយ Specialization តាមប្រទេសបានធ្វើឲ្យបរិមាណរថយន្តផលិតបានកើន ៣៥ ឯកតា និងក្រូចកើន ៥០ ឯកតា។

# វិលរ៉ាស់ Leon Walras

# ១៨៣៤-១៩១០

វិលរ៉ាស់ជាអ្នកសេដ្ឋកិច្ចគណិតវិទ្យាបារាំង ដែលបានរកឃើញទ្រឹស្តីសមតា ក្នុងទីផ្សារសេដ្ឋកិច្ច។ វិលរ៉ាសដំបូង មានបំនងចង់រៀនវិស្វករ ប៉ុន្តែបានទទួលឥទ្ធពលពីគំនិតសេដ្ឋកិច្ចរបស់ឪពុកគាត់។

## ១. សមតាទូទៅ General Equilibrium

សមតាទូទៅ ចង់សំដៅ ថ្លៃផលិតផលជាអ្នក clear នៅពេលដែលការផ្គត់ផ្គង់ស្មើរតម្រូវការ ដោយខុសផ្លែកពី គំនិតម៉ាស្យល់បរិមាណ ជាអ្នក Clear ទីផ្សារ។

## ២. ទ្រឹស្តីរបស់វិលរ៉ាស់

មានអ្នកមានផលិតផល ចង់ទៅដោះដូរផលិតផលរបស់ខ្លួនក្នុងទីផ្សារ៖

$$mv_a=nv_b$$

m ជាចំនួននៃផលិតផល A ដែលយើងចង់ដោះដូរ n ជាចំនួននៃផលិតផល B ដែលយើងចង់ដោះដូរ។ $v_a$ និង $v_b$ជាអត្រាដោះដូរនៃផលិតផល A និង B។

$$v_b/v_a=p_b=m/n=\mu$$

$$v_a/v_b=p_a=n/m=1/\mu$$

ថ្លៃ Price p ជាបញ្ច្រាសនៃផលធៀបបរិមាណដោះដូរ។

$D_a$, $O_a$, $D_b$ ,និង$O_b$ ជាតម្រូវការផលិតផល A ការស្នើរដោះដូរផលិតផល A ជាតម្រូវការផលិតផល B និងការស្នើរដោះដូរផលិតផល B យើងបាន៖

$$O_a=D_b\ p_b$$

$$D_a=O_b\ p_b$$



# J.M. Keynes

## Demand, Liquidity Preference, Big Government

# ខេន J.M. Keynes
# ១៩៨៣-១៩៤៦

ខេនបានសរសេរសៀវភៅ The General Theory of Employment, Interest and Money ដែលបានបដិវត្តសេដ្ឋកិច្ចវិទ្យា ទៅលើ Classic សេដ្ឋកិច្ចវិទ្យា។ ខេនត្រូវបានគេចាត់ទុកជាបិតាម៉ាក្រូសេដ្ឋកិច្ចសព្វថ្ងៃ។ ខេន បានចូលរៀនទស្សនវិជ្ជា និងគណិតវិទ្យានៅសាកលវិទ្យាល័យខាំប្រីដ្ស ហើយបានចូលរៀនសេដ្ឋកិច្ចនៅទីនោះ។

**១. កង្វះតម្រូវការ Effective Demand**

បើយោងតាម Say Law ការផ្គត់ផ្គង់នឹងកំណត់ Output សម្រាប់សេដ្ឋកិច្ច។ ក៏បន្ដែវិបត្តិ The Great Depression ១៩៣១ មានការផលិតលើសផលិតផលលក់មិនចេញ ដែលធ្វើឲ្យក្រុមហ៊ុនរោងចក្របានបណ្តេញកម្មករចេញពីរោងចក្រផលិត ដែលបណ្តាលឲ្យមាន និកម្មភាពមិនស្ម័គ្រចិត្ត Involuntary

Unemployment។ ខេនបានចេញទ្រឹស្តីដើម្បីបង្កើតតម្រូវការ ត្រូវតែបង្កើនការប្រើប្រាស់ Consumption និងការវិនិយោគ Investment។

Y=C+I

## ២. Marginal Propensity to Consume

ការប្រើប្រាស់នឹងកើនឡើងតាមការកើនឡើងនៃចំណូល។

$$MC = \frac{\Delta C}{\Delta Y}$$

$$0 < MC < 1$$

## ៣. មេគុណ Multiplier

មេគុណ Multiplier បានន័យថាបើ វិនិយោគកើនឡើង នឹងបង្កើតចំណូលបានប៉ុន្មាន។ ឧទាហរណ៍៖ បើសិនវិនិយោគកើន ១០០ លាន ចំណូលនឹងកើន ១០០ លានដូចគ្នា MC c ការប្រើប្រាស់ ០,៨ ការប្រើប្រាស់កើន ៨០ លានដែរ។

$$\Delta Y = \frac{1}{1-c}\Delta I$$

$$\Delta Y = \frac{1}{1-0.8}100 = 500$$

ដូចនេះគ្រាន់តែបង្កើនវិនិយោគ ១០០ លាន បានធ្វើឲ្យកើនចំណូលបាន ៥០០លាន។

## ៤. Liquidity Preference

ដើម្បីយល់ពី Liquidity បើសិនយើងយកលុយ ក្រដាស ១០០$ ទៅទិញទំនិញធម្មតា ដូចបារី ឬកូកា ១ កំប៉ុង អ្នកលក់នឹងមានការលំបាកយកលុយ ១០០$ ឬមិនអាចលក់ឲ្យ។ ក្នុងទិដ្ឋភាពនេះ លុយ ១០០$ មាន Liquidity ទាបមែនទែន។ ប្រើប្រាក់បញ្ញើរនៅធនាគារ ដែលអាចដកបានភ្លាម មាន Liquidity ខ្លាំងជាង ប្រាក់បញ្ញើរតាមកាលកំណត់។ មូលបត្រ មិនសូវមាន Liquidity ប៉ុន្តែយើងអាចភាគលាភ តាមកាលកំណត់ ដូចនេះបាន

ខេន បាននិយាយថា ការប្រាក់ i ដែលយើងបានពីមូលបត្រ ជា Reward នៃ Liquidity Preference។

ខេនបានកំណត់ តម្រូវការលុយដោយសារៈ

- ការចំណាយសម្រាប់ការប្រតិបត្តិការសេដ្ឋកិច្ចប្រចាំថ្ងៃ Y។ កាលណា Y កាន់តែកើន តម្រូវការលុយកាន់តែកើន។
- ការត្រូវការលុយដើម្បីទិញមូលបត្រ ឬផ្ញើរដើម្បីយកការប្រាក់។ កាលណាការប្រាក់ i កាន់តែកើនឡើង យើងកាន់តែមិនទុកលុយក្នុងដៃ។
- តម្រូវការលុយសម្រាប់ការប្រើប្រាស់ក្នុងពេលខាងមុខ។

ដូចនេះយើងបានសមីការៈ

$$\frac{M}{P} = L_1^{(+)}(Y) + L_2^{(-)}(i)$$



# Milton Friedman

## Monetarism, Small Government, Liberalism

# ហ្វ្រីដមែន M. Friedman

## ១៩១២-២០០៦

ហ្វ្រីដមែនជាសាស្ត្រាចារ្យនៅសាកលវិទ្យាល័យឈីខាហ្គោ និងគាត់បានទទួលណូបែលសេដ្ឋកិច្ចក្នុងឆ្នាំ ១៩៧៦។ គាត់ជាបិតានៃសេដ្ឋកិច្ចវិទ្យារូបិយវត្ថុ Monetarism ដ៏ល្បីល្បាញ។ គាត់ក៏ជាអ្នកស្ថិតិវិទូដែលគាត់រកឃើញ តេស្តមួយស្ថិតិ ដែលយើងហៅថា Friedman Test។ ហ្វ្រីដមែនបានសង្កត់ធ្ងន់វិបត្តិ The Great Depression ១៩៣១ អាចជៀសវាងបានបើសិន ធនាគារកណ្តាកសហរដ្ឋអាមេរិក ធ្វើការផ្គត់រូបិយវត្ថុទាន់ពេលវេលាដល់ធនាគារពាណិជ្ជដែលបានដួលរលំ។ ហ្វ្រីដមែនមានគំនិតសេរីនិយម ដែលមិនចង់ឲ្យរដ្ឋាភិបាលលូកដៃចូលសេដ្ឋកិច្ច ឬប្រព័ន្ធអប់រំ ដែលគំនិតគាត់ហៅថា Small Government។

### ១. លក្ខណៈនៃសេដ្ឋកិច្ចរូបិយវត្ថុ Monetarism

Monetarism ជាទ្រឹស្តីមួយដែលមានការប្រកួតប្រជែងជាមួយទ្រឹស្តីខេន Keynesianism។ លក្ខណៈនៃទ្រឹស្តីរូបិយវត្ថុមានដូចជា៖

- ការផ្គត់ផ្គង់រូបិយវត្ថុ ធ្វើឲ្យមានកំណើនសេដ្ឋកិច្ច
- រដ្ឋាភិបាលអាចគ្រប់គ្រងការផ្គង់រូបិយវត្ថុ
- ការផ្គត់ផ្គង់រូបិយវត្ថុត្រូវធ្វើបេរ និងមិនជាកញ្ចប់ដែលដោយតាមកាល Discretion
- ទំហំស្តុកនៃរូបិយវត្ថុ មានឥទ្ធិពលដល់សេដ្ឋកិច្ច

២. Friedman's k-percent rule

តាមគំនិតរបស់ ហ្វ្រីដមែន ធនាគាកណ្តាលរបស់ប្រទេសនីមួយ គួរតែបង្កើនការផ្គត់ផ្គង់រូបិយវត្ថុ ក្នុងអត្រាមួយបេរ តាមកំណើនសេដ្ឋកិច្ច។

ហ្វ្រីដម៉ែនតែងតែបញ្ជាក់ថារដ្ឋាភិបាលត្រូវតែធ្វើការផ្គត់ផ្គង់រូបិយវត្ថុ នៅពេលដែលវិស័យឯកជនត្រូវការសាច់ប្រាក់។

នៅក្នុងសៀវភៅរបស់គាត់ A Monetary History of United State យើងឃើញមានការនិយាយពីការផ្គត់ផ្គង់រូបិយវត្ថុ

$$M=C+D$$

ដែល M ជារូបិយវត្ថុដែលបានផ្គត់ផ្គង់ C ជារូបិយវត្ថុក្រោធនាគារ និង D ជារូបិយវត្ថុបញ្ញើរនៅធនាគារកណ្តាល។

$$H=C+R$$

ដែល H ជា High Power Money និង R ជា Reserve Requirement របស់ធនាគារពាណិជ្ជនៅធនាគារកណ្តាល។

$$\frac{M}{H}=\frac{C+D}{C+R}$$

អត្រាប្រាក់បញ្ញើរធនាគារពាណិជ្ជធៀបនឹងរូបិវត្ថុ ក្រៅធនាគា D/C=a និងអត្រា Reserve Requirement ធនាគារពាណិជ្ជដាក់នៅធនាគារកណ្តាល R/C=b ដូចនេះយើងបាន៖

$$M = \frac{1+a}{1+b}H$$

ជាគោលនយោបាយរូបិវត្ថុ បើយើងគ្រាន់តែកែប្រែអត្រា b ក៏ជាការផ្គត់ផ្គង់រូបិយវត្ថុដែរ។

### ៣. Permanent income hypothesis

Permanent income hypothesis បានបង្ហាញ ថាមនុស្សក្នុងសេដ្ឋកិច្ចនឹងធ្វើការចំនាយរបស់ខ្លួនដោយគិតពីការចំនាយនៅពេលអនាគត ដែលខុសផ្លែកពីគំនិតរបស់ខេន ថាមនុស្ស

ក្នុសេដ្ឋកិច្ចនឹងចំនាយ ពីចំណូលរបស់ខ្លួនក្រោយពីដកពន្ធ ដែល ការកំណត់ពន្ធលើប្រាក់ចំណូល នឹងធ្វើឲ្យមានឥទ្ធិពលដល់ការ ប្រើប្រាស់។

## ៤. ល្បឿននៃលុយ Velocity of Money

Velocity នៃ Money ត្រូវបាន លោកហ្រ្វីដមែនប្រើ សម្រាប់វិភាគសេដ្ឋកិច្ចរបស់គាត់ A Monetary History of United State។

$$MV = PT$$

ដែល M ជាការផ្គត់ផ្គង់រូបិយវត្ថុ V ជា Velocity P ជាថ្លៃក្នុងសេដ្ឋ កិច្ច T ជាចំនួន Transaction ក្នុសេដ្ឋកិច្ច។ ជាទូទៅ គេសរសេ

$$MV = PY$$

ដែល Y ជា GDP ។ បើ Velocity កើនឡើងមានន័យថា រូបិយវត្ថុ បានបម្រើឲ្យសកម្មភាពសេដ្ឋកិច្ចច្រើនឡើង។

## ៥. Friedman Test

Friedman Test គឺជា Non-parametric តេស្ត ដែលបានកំណត់ Rank ទិន្នន័យ និងឲ្យគោរពតាម Chis-square Distribution។

## ៦. បទពិចារណាចំពោះទ្រឹស្តីរបស់ Friedman

ចំពោះបញ្ហាផ្គត់ផ្គង់រូបិយវត្ថុ របស់ធនាគារកណ្តាលជប៉ុន ដែលបានបណ្តាលឲ្យមាន Bubble ទៅតំលៃដី និងតម្លៃមូលបត្រ ដែលឡើងថ្លៃយ៉ាងសម្បើម ដែលធ្វើឲ្យមានវិបត្តិបំណុល ក្រោយពី Bubble។ ដោយសារបញ្ហា Plaza Agreement ដែលដំឡើងតម្លៃលុយយ៉េនជប៉ុន ពី ២០០យ៉េន/$ ទៅ ១០០យ៉េន/$ ធនាគារកណ្តាលជប៉ុនបានបន្ធូរូបិយវត្ថុ ប៉ុន្តែធនាគារពាណិជ្ជរបស់ជប៉ុនបានបង្កើនកំចី ទៅវិស័យអចលនៈ ដែលធ្វើឲ្យមាន Bubble កើតឡើង។



Robert Solow

Economic Growth

# រ៉ូប៊ែតសូឡូវ Robert Solow
# (១៩២៧-សព្វថ្ងៃ)

រ៉ូប៊ែតសូឡូវបានទទួលណូបែលសេដ្ឋកិច្ចក្នុងឆ្នាំ ១៩៨៧ សម្រាប់ការរកឃើញរបស់គាត់ដែលហៅ ថា Exogenous Growth Model។ គាត់ជាសាស្ត្រាចារ្យសេដ្ឋកិច្ច នៅ MIT សហរដ្ឋអាមេរិក និងគាត់បានចូលសិក្សានៅ Harvard College។

ម៉ូដែលរបស់គាត់ដែលមានឈ្មោះថា Solow-Swan Model មានភាពល្បីល្បាញក្នុងម៉ាក្រូសេដ្ឋកិច្ច។ ក្នុងម៉ូដែលរបស់គាត់ កំណើនសេដ្ឋកិច្ចត្រូវបានកើនកំណើននៃមូលនិធិ Capital ស្របតាមកំណើនប្រជាជន និងការរីកចម្រើននៃបច្ចេកវិជ្ជាផលិត។

**Solow–Swan model៖**

ក្នុងសេដ្ឋកិច្ច៖

$$Y(t) = K(t)^{\alpha}(A(t)L(t))^{1-\alpha}$$

Y ជាផលិតផលជាតិសរុប K ជាមូលធន A ជាបច្ចេកវិជ្ជា L ជាកម្លាំងពលកម្ម។

$$\dot{K(t)} = sY(t) - \delta K(t)$$

$$\dot{K(t)} = \frac{dK(t)}{dt}$$

ដែល កំណើននៃ Capital ម៉ាស៊ីនក្នុងរោចក្រ K(t) គឺបានមកពីសន្សំ s ដែលធៀបនឹងផលិតផលសរុប ដកនឹងរំលួស ការខូច ឬសឹករិករិលនៃគ្រឿងម៉ាស៊ីន $\delta$ ។

$$y(t) = \frac{Y(t)}{A(t)L(t)} = k(t)^{\alpha}$$

យើងចែក ផលិតផលសរុប ក្នុងមនុស្សម្នាក់។

$$\dot{k(t)} = sk(t)^{\alpha} - (n + g + \delta)k(t)$$

ដោយ n ជាកំនើប្រជាជន និង g ជាកំណើនបច្ចេកវិជ្ជា។

នៅក្នុងសមតា Steady State $\dot{k(t)} = 0$ ដូចនេះ៖

$$sk(t)^{\alpha} - (n + g + \delta)k(t) = 0$$

ស្តុកនៃមូលធនដែលសេដ្ឋកិច្ចសម្រេចបាន៖

$$k^* = \left(\frac{s}{n + g + \delta}\right)^{\frac{1}{1-\alpha}}$$

ដូចនេះដើម្បីរក្សាកំណើនសេដ្ឋកិច្ច ត្រូវទាមទារអត្រា សន្សំ s ឲ្យមានលំនឹង។ កាលណា អត្រាសន្សំផ្សេងគ្នានឹងបណ្ដាលឲ្យមាន growth path ផ្សេងគ្នាសម្រាប់សេដ្ឋកិច្ច។



# Paul Samuelson

Equilibrium Stability, Mathematical Economics

# ផូលសាមុអែលសន (P. Samuelson)
## (១៩១៥-២០០៩)

សាមុអែលសន ជាជនជាតិអាមេរិកាំងទី១ ដែលបានទទួលពានរង្វាន់ណូបែលសេដ្ឋកិច្ច។ គាត់បានបណ្ឌិតសេដ្ឋកិច្ចពីសាកវិទ្យាល័យ Harvard និងសាស្ត្រាចារ្យសេដ្ឋកិច្ចនៅ MIT។ គាត់បានផ្តល់វិភាគទានដល់ការធ្វើឲ្យសេដ្ឋកិច្ចក្លាយជាគណិតវិទ្យា។ ស្នាដៃរបស់គាត់ គឺការស្វែងរកស្ថេរភាពលក្ខណ្ឌសម្រាប់សមតា។

បើសិនយើងមាន ប្រព័ន្ធសមីការនៃអញ្ញត្តិ $x$ ដែលយើងមិនដឹង និង $\alpha$ ជាអញ្ញត្តិកំណត់ជាមុន៖

$$f^{i}(x_1, \dots x_n, \alpha) = 0$$

បើយើងកំណត់អញ្ញត្តិស្ថិតក្នុងសមតា៖

$$x_i^0 = g_i'(\alpha)$$

ដើម្បីរកចំនុសមតាយើងដេរីវេ៖

$$\frac{dx_i^0}{d\alpha} = -\frac{\sum_i^n f_\alpha \Delta_{ji}}{\Delta}$$

ដោយ

$$\Delta = \begin{bmatrix} f_1^1, \dots, f_n^1 \\ f_1^2, \dots, f_n^2 \\ \dots \dots \dots \dots \\ f_1^n, \dots, f_n^n \end{bmatrix}$$

ជាឧទាហរណ៍៖ ក្នុងសមីការនៃការផ្គត់នៃការផ្គត់ផ្គង់ យើងមានអញ្ញត្តិដែលត្រូវរកមាន ថ្លៃ $p$ និងបរិមាណ $q$ និងអញ្ញត្តិចំនង់ចំនូលចិត្ត $\alpha$ ៖

$$q - D(p, \alpha) = 0$$

$$q - S(p) = 0$$

$$\frac{dp^0}{d\alpha} = D_\alpha^0 \frac{1}{S_p^0 - D_p^0}$$

$$\frac{dx^0}{d\alpha} = D_\alpha^0 \frac{S_p^0}{S_p^0 - D_p^0}$$

លក្ខខណ្ឌនៃស្ថិរភាពនៃសមតា៖

$$\lim_{t \to \infty} x(t)_i = x_i^0$$

ជាឧទាហរណ៍៖

$$\dot{p} = \frac{dp}{dt} = H(q_D - q_S) = H(D(p,) - S(p))$$

$$\dot{p} = \lambda\left(D_p^0 - S_p^0\right)(p - p^0) + \cdots$$

$$p(t) = p^0 + (\bar{p} - p^0)e^{\lambda\left(D_p^0 - S_p^0\right)t}$$

$$\lim_{t \to \infty} p_t = p^0$$

ក្នុងលក្ខណ្ឌ៖ $\boldsymbol{D_p^0 - S_p^0 < 0}$

ការពិចារណាទ្រឹស្តីរបស់សាមុអែលសុន៖

នៅក្នុងប្រព័ន្ធសមីការនៃការផ្គត់ផ្គង់ និងតម្រូវការ យើងអញ្ញត្តិ Endogenous ថ្លៃ p និងបរិមាណ q។ នៅក្នុងសេដ្ឋមាត្រសាស្ត្រមានបញ្ហាកំណត់មិនបាន Identification Problem ដោយ

យើងកំណត់មិនបានលើទិន្នន័យ ដោយយើងមិនដឹង ថាទិន្នន័យនេះជាទិន្នន័យ តម្រូវការឬផ្គត់ផ្គង់។ អាស្រ័យហេតុដូចនេះយើងត្រូវការអញ្ញត្តិ Exogenous មួយដូចជា $\alpha$ ដែលជា Taste ជាដើម ហើយដោះស្រាយប្រព័ន្ធសមីការជា Reduced Form ។



# George Akerlof

## Information Asymmetry

# ចច អាកេឡូហ្វ George Akerlof

## (១៩៤០-សព្វថ្ងៃ)

ចចអាកេឡូហ្វ ជាសាស្ត្រាចារ្យសេដ្ឋកិច្ចនៅសាកលវិទ្យាល័យកាលីហ្វ័រណ្ញា។ គាត់បានទទួលរង្វាន់ណូបែលសេដ្ឋកិច្ចក្នុងឆ្នាំ ២០០១ សម្រាប់ទ្រឹស្តីពត៌មានក្នុងទីផ្សារសេដ្ឋកិច្ច Asymmetric Information។ Paper របស់គាត់ត្រូវបាន Top Journal ចំនួន ៤ បានបដិសេធ តែចុងក្រោយ Quarterly Journal ទទួលបោះពុម្ភ។

ទ្រឹស្តី Asymmetric Information របស់គាត់អំពីទីផ្សារឡានជជុះ (Lemon Car) ដែលអ្នកទិញមិនដឹងពីគុណភាពរបស់ឡានជជុះនោះ ដែលពេលខ្លះ ទិញប៉ះឡានគុណភាពល្អ និងគុណភាពមិនល្អ។ កាលណាអ្នកទិញ ទិញប៉ះឡានមិនល្អជាច្រើន នោះអ្នកទិញទាំងអស់ ឈប់ទុកចិត្តទីផ្សារឡានជជុះ ហ្នឹងតែម្តង នឹងធ្វើឲ្យរលំទីផ្សារឡានជជុះ ហ្នឹងតែម្តង។

នៅក្នុង Paper របស់អាកេឡូហ្វ៖

មានអ្នកជំនួញ ២ ក្រុមដែលមានសមីការប្រើប្រាស់៖

$$U_1 = M + \sum_{1}^{n} x_i$$

$M$ ជាការប្រើប្រាស់ក្រៅពីការទិញរថយន្តជជុះ និង $x_i$ ជាការប្រើប្រាស់លើគុណភាពរថយន្តជជុះ។

$$U_2 = M + \sum_{1}^{n} 3/2x_i$$

$D_1$ ជាតម្រូវការរថយន្តសម្រាប់អ្នកជំនួញ ទី១ $Y_1$ ជាចំនួលរបស់ពួកគាត់ $\mu$ ជាគុណភាពរថយន្តជជុះ $p$ ជាថ្លៃរថយន្តជជុះ៖

$$D_1 = Y_1/p \qquad \mu/p > 1$$

$$D_1 = 0 \qquad \mu/p < 1$$

បានន័យថាអ្នកជំនួញទី១ មិនទិញរថយន្ត ពើសិនគុណភាពទាបជាងតម្លៃ $\mu/p < 1$ ។

ការផ្គត់រថយន្តទិញសម្រាប់លក់ ដែគុណភាពឡាន $0 \leq x \leq 2$ និង $N$ ចំនួនឡានសរុប។

$$S_2 = pN/2 \qquad p \leq 2$$

គុណភាពឡានជាមធ្យម

$$\mu = p/2$$

ដូចគ្នានេះដែរតម្រូវការឡានសម្រាប់អ្នកជំនួញទី២៖

$$D_2 = Y_2/p \qquad 3\mu/2p > 1$$

$$D_2 = 0 \qquad 3\mu/2p < 1$$

និង

$$S_2 = 0$$

នៅពេលដែលមានពត៌មានត្រឹមត្រូវអ្នកផ្គត់ផ្គង់ឡានដែលមានតែគុណភាព៖

$$S(p) = N \qquad p > 1$$

$$S(p) = 0 \qquad p < 1$$



John Nash

Non-cooperative Game, Mathematics

# ចនណាស្ស John Nash
# ១៩២៨-២០១៥

ចនណាស្ស ត្រូវបានចាត់ទុកជា Genius ជាមួយទ្រឹស្តីរបស់គាត់ ល្បែងមិនសហការ Non-cooperative Game ដែលគណិតវិទ្យាដ៏ស្រស់ស្អាតក្នុងល្បែងទ្រឹស្តី Game Theory។ គាត់បានទទួលពានរង្វាន់ណូបែលសេដ្ឋកិច្ច ក្នុងឆ្នាំ ១៩៩៥។ គាត់ជំងឺ Schizophrenia ហើយត្រូវបានភាពយន្ត Beautiful Mind សម្តែងពីជីវិតរបស់គាត់។ គាត់បានចូលរៀនគណិតវិទ្យានៅសាកលវិទ្យាល័យព្រីនស្តុន និងបានក្លាយជាសាស្ត្រាចារ្យ នៅសាកលវិទ្យល័យនោះ។

ល្បែងមិនសហការ Non-cooperative game គឺជាល្បែងទ្រឹស្តី ដែលអ្នកយុទ្ធសាស្ត្រ នឹងចេញយុទ្ធសាស្ត្ររបស់ខ្លួន ដោយផ្អែកលើជំហ៊ានរបស់គូរបដិបក្ខ។

## ១. ល្បែងការស្ទួរចម្លើយអ្នកទោស

ឧទាហរណ៍ថាមានអ្នកទោស ២ នាក់ត្រូវបានចាប់បាន ដែលបានធ្វើខុសច្បាប់រួមគ្នា។ ប៉ូលីសបានសួរចម្លើយ និងអ្នកទោសទាំងពីរ មានយុទ្ធសាស្ត្រ ១) សារភាព និង ២)មិនសារភាព និងទោសជាប់ពន្ធធនាគារដូចខាងក្រោម៖

| | អ្នកទោសទី២ សារភាព | អ្នកទោសទី២ មិនសារភាព |
|---|---|---|
| អ្នកទោសទី១ សារភាព | 3,3 | 1,4 |
| អ្នកទោសទី១ មិនសារភាព | 4,1 | 2,2 |

ចំនួនលេខគឺជាចំនួនឆ្នាំ នៃការជាប់ទោស បើសិនសារភាពទាំងពីរនាក់ អ្នកទាំងពីរ នឹងជាប់ទោសស្មើរគ្នា ៣ ឆ្នាំម្នាក់ បើសិនមានម្នាក់សារភាព ម្នាក់មិនសារភាព អ្នកសារភាព ជាប់ ១

ឆ្នាំ អ្នកមិនសារភាពជាប់ ៤ ឆ្នាំ។ ដូចនេះ Nash Equilibrium ណាស្សសមតា មិនសារភាពទាំង ២ នាក់ ដែលជាប់ទោស ២ ឆ្នាំម្នាក់។

## ២. យុទ្ធិសាស្រ្តចំរុះ Mixed Strategy

| | ក្រុមហ៊ុន 2 យុទ្ធសាស្រ្ត A | ក្រុមហ៊ុន 2 យុទ្ធសាស្រ្ត B |
|---|---|---|
| ក្រុមហ៊ុន 1 យុទ្ធសាស្រ្ត A | 3,2 | 1,1 |
| ក្រុមហ៊ុន 1 យុទ្ធសាស្រ្ត B | 0,0 | 2,3 |

ចំនួនលេខក្នុងជាយអឺក្រោមជា Payoff ចំនេញរបស់ក្រុមហ៊ុន ១ និង ២ សម្រាប់ការប្រើយុទ្ធសាស្រ្ត A និង B។

យើងយក p និង q ជាកម្រិតនៃការប្រើយុទ្ធសាស្រ្តទាំងពីរចូលគ្នា៖

$P_1=pP_A+(1-p)P_B$

សមតាបានន័យ Payoff function ស្មើរគ្នារវាងយុទ្ធសាស្រ្តទាំងពីរ Optimal នឹងយុទ្ធសាស្រ្តគូរបដិបក្ខ។

ដូចនេះយើងបាន៖

$3p+1(1-p)=0p+2(1-p)$

$4p=2$

$p=0.5$

ដូចនេះក្រុមហ៊ុនទី១ ប្រើយុទ្ធចំរុះ Mixed Strategy៖

$$\pi = 0.5A + 0.5B$$



Robert Mundell

OCA, International Economics

# ម៉ាន់ដែល R. Mundell

## ១៩៣២-១៩២១

ម៉ាន់ដែលជាអ្នកសេដ្ឋកិច្ចកាណាដា ដែលបានចេញទ្រឹស្តី Optimum Currency Area ហើយទទួលបានពានរង្វាន់ណូបែលសេដ្ឋកិច្ចក្នុងឆ្នាំ ១៩៩៩ និងគាត់បាន ល្បីល្បាញសម្រាប់ Mundell-flemming Model នៃពាណិជ្ជកម្មអន្តរជាតិ។

ម៉ានដែលបានសង្កត់ធ្ងន់ថា ការប្រើប្រាស់តំបន់ប្រើរូបិយបណ្ណរួម នឹងធ្វើឲ្យចំនេញទុនបម្រុង អាចស្រូបយកហានិភ័យរួមបាន Cushion the Common Shock រួមបាន។

**១) ការស្រូបយកហានិភ័យ Cushion the Common Shock**

ឧទាហរណ៍ក្នុងពិភពលោកមួយនេះ មានប្រទេសកោះ ២ ឈ្មោះថា Capricorn និង Aquarius ដែលមានអាកាសធាតុផ្សេងគ្នាតាមគន្លងអឌ្ឍគោលផែនដី ដូចនេះការប្រកបកសិកម្មសម្រាប់ការចិញ្ចឹមជិវិតរបស់ប្រជាជនបានតែកន្លះឆ្នាំម្នាក់។

ដោយសារអាកាសធាតុផ្សេងគ្នា ក្នុងកន្លះឆ្នាំដំបូង Capricorn ដាំកសិកម្ម ហើយបានផល ដូចនេះតម្រូវឲ្យប្រជាជន Aquarius ត្រូវចំនាយលុយ ដើម្បីទិញលុយ Capricorn ពីទុនបម្រុងរបស់ធនាគារកណ្តាលខ្លួន ដើម្បីទីញផលិតផលកសិកម្មពី Capricorn ។ ដល់ ៦ ខែក្រោយមក ប្រជាជន Capricorn ក៏ត្រូវធ្វើដូចប្រជាជន Aquarius ដើម្បីទិញផលិតកសិកម្ម។

ប៉ុន្តែក្នុងឆ្នាំ ១ ផលិតកម្មកសិកម្មរបស់ Capricorn ត្រូវបានខូចពាក់កណ្តាល ដូចការផ្គត់ផ្គង់ធ្លាក់ចុះ។ រដ្ឋាភិបាល Capricorn មានបញ្ហាមិនអាចផ្គត់ផ្គង់គ្រប់ចំនួនដល់ Aquarius ហើយគួរតែសម្រេចចិត្ត បញ្ចុះតម្លៃរូបិយបណ្ណរបស់ខ្លួនឬយ៉ាងណា? ប៉ុន្តែបើប្រទេសកោះទាំងពីរ Capricorn មិនចាំបាច់បញ្ចុះតម្លៃរូបិយបណ្ណខ្លួនទេ បើសិន ប្រជាជនប្រទេសទាំងពីរ ប្រើលុយរួមតាមទិញតាមការផ្គត់ផ្គង់របស់ទីផ្សារ។

## ២. លក្ខខណ្ឌសម្រាប់ប្រទេសដែលអាចមានរូបិយបណ្ណរួម

ទ្រឹស្តី Optimum Currency Area របស់ Mundell ដើម្បីសេដ្ឋកិច្ចរបស់ប្រទេសពីរអាចធ្វើសមាហរណកម្មជាមួយគ្នាបានលុះត្រា៖

- កម្លាំងពលកម្មអាចផ្លាស់ប្តូរដោយសេរីរវាងប្រទេសទាំងពីរ
- ប្រទេសទាំងពីរមានពាណិជ្ជកម្មរួមគ្នាច្រើន
- មានការផ្លាស់ប្តូរដោយសេរីរវាងមូលធន ជាមួយនឹងភាពរស់រវើកនៃ អតិផរណា និងប្រាក់ឈ្នួល
- ប្រទេសទាំងពីរមានប្រពន្ធអាចស្រូបយកហានិភ័យរួមគ្នា
- ប្រទេសទាំងពីរមានវដ្តសេដ្ឋកិច្ចប្រហាក់ប្រហែលគ្នា



Rudie Dornbusch

Overshooting Model

# ដុនប៊ុស្ស Rudie Dornbusch

## ១៩៤២-២០០២

ដុនប៊ុស្ស ជាអ្នកសេដ្ឋកិច្ចអាមេរិក ដែលល្បីល្បាញសម្រាប់ Overshooting Model។ ដុនប៊ុស្ស ជាជនជាតិអាឡឺម៉ង់ និងជាសិស្សរបស់ ម៉ាន់ដែល។ សិស្សរបស់គាត់ដែលជាអ្នកសេដ្ឋកិច្ចល្បីល្បាញ គឺ ផូល គ្រុម៉េន Paul Krugman ដែលបានទទួលណូបែលសេដ្ឋកិច្ច។ ផូល គ្រុម៉េន បាននិយាយថាគ្រូរបស់ខ្លួន ដុនប៊ុស្ស ជំរុញឲ្យអានព័ត៌មានសេដ្ឋកិច្ចជាប្រចាំ។

Overshooting Model៖

ជាម៉ូដែលបាននិយាយតម្រូវការទីផ្សារផលិតផល និងការផ្គត់ផ្គង់រូបិយវត្ថុ។




Overshooting Model របស់ ដុនប៊ុស្ស បានបង្ហាញថា នៅពេលដែល រដ្ឋាភិបាលបង្កើនការផ្គត់ផ្គង់រូបិយវត្ថុ នឹងធ្វើឲ្យរូបិយបណ្ណក្នុងប្រទេស ចុះថោក ប៉ុន្តែតម្លៃទំនិញ មិនទាន់កើនទេ។ អស់រយៈពេលមួយ ថ្លៃទំនិញចាប់ផ្តើមកើន និងរូបិយបណ្ណចាប់ផ្តើមឡើងថ្លៃមកវិញ។ ដូចនេះ ការបន្កើនបរិមាណរូបិយបណ្ណនឹងធ្វើឲ្យ Overshoot អត្រាផ្តូរប្រាក់។



Paul Krugman

New Trade Theory, Currency Crisis

# ផូលគ្រូម៉ែន Paul Krugman
# ១៩៥៣-សព្វថ្ងៃ

ផូល គ្រូម៉ែនជាសិស្សរបស់ ដុនប៊ុស្ស និងជាអ្នកសេដ្ឋកិច្ចដ៏ល្បីល្បាញកក្នុងពិភពលោក។ គាត់បានទទួលពានរង្វាន់ណូបែលសេដ្ឋកិច្ច ក្នុងឆ្នាំ ២០០៨ សម្រាប់ការរកឃើញ New Trade Theory។ គ្រូម៉ែនជាសាស្ត្រាសេដ្ឋកិច្ចរបស់ MIT។

## ១) ទ្រឹស្តីពាណិជ្ជកម្មថ្មី New Trade Theory

នាសម័យកាលមុន ទ្រឹស្តីពាណីជ្ជកម្មតែងតែយោងទ្រឹស្តីអត្ថប្រយោជន៍ធៀបរបស់ រីកាដូ។ ប៉ុន្តែ ផូលគ្រើម៉ែន រកឃើញថាក្រុមហ៊ុនពិភពលោកសព្វថ្ងៃ ធ្វើពាណិជ្ជកម្មដោយ Economy of Scale ដែលផលិតផលិតផល ក្នុងថ្លៃដើមទាប និង Product Diversification ការធ្វើផលិតផលជាច្រើនប្រែន ឬម៉ាក។

## ២) ទ្រឹស្តីវិបត្តិហិរញ្ញវត្ថុ

ទ្រឹស្ដីវិបត្តិហិរញ្ញវត្ថុរបស់ ផូលគ្រូម៉េន ត្រូវបានគេឲ្យឈ្មោះ ទ្រឹស្ដីវិបត្តិហិរញ្ញវត្ថុជំនាន់ទី ២ ។

$$\frac{\dot{M}}{P} = G - T$$

ទ្រឹស្ដីវិបត្តិនេះ បានបង្ហាញ ពីការបង្គ្រប់ចំនាយរដ្ឋាភិបាល ដោយការបោះពម្ពលុយ ដែលធ្វើមនុស្សក្នុងសេដ្ឋកិច្ច ចាប់ផ្ដើម បោះបង់រូបិយបណ្ណក្នុងស្រុក ហើយយករូបិយបណ្ណបរទេស ដែល ធ្វើទុនបម្រុងធនាគារកណ្ដាលអស់ តាមរយៈ Speculative Attack។

# ឯកសារយោង


- Adam Smith ( 1776 ) An inquiry into the nature of cause of wealth of nation
- Walras ( 1874 ) Element of pure economics
- Ricardo ( 1817 ) On the principle of economy and taxation
- Karl Marx ( 18630 ) Capital
- Hume ( 1739 ) A treatise of human nature
- Nash ( 1951 ) Noncooperative game, Anal of mathematics
- Samuelson ( 1931 )The Stability of Equilibrium: Comparative Statics and Dynamics, Econometrica
- Mundell, An argument for currency union
- Friedman ( 1965 ) A monetary history of United State
- Akerlof ( 1970 ) The market for lemon

**ជឹម សុជាតិ៖** អ្នកស្រាវជ្រាវ នៃរាជបណ្ឌិត្យសភាកម្ពុជា ធ្លាប់មានបទពិសោធន៍ការងារ ក្រសួងការងារបណ្តុះបណ្តាលវិជ្ជាជីវៈ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រុមហ៊ុនជប៉ុន

**១៩៨៣** កើតនៅខេត្តកណ្តាល

**២០០៨** បញ្ចប់ការសិក្សាបរិញ្ញាប័ត្រសេដ្ឋកិច្ចពី Kyushu University

**២០១០** បញ្ចប់ការសិក្សាអនុបណ្ឌិតសេដ្ឋកិច្ចពី Osaka University